# របាយការណ៍លទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣
# របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តត្បូងឃ្មុំ

## សេចក្តីផ្តើម

ខេត្តត្បូងឃ្មុំជាខេត្តស្ថិតនៅវាលទំនាបកណ្តាលនៃទន្លេមេគង្គ និងនៅទិសបូព៌ានៃប្រទេសកម្ពុជា មានចម្ងាយប្រមាណ ១៦៩ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៧។ ខេត្តត្បូងឃ្មុំ មានព្រំប្រទល់ ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងជើងជាប់នឹងខេត្តក្រចេះ ខាងលិចជាប់នឹងខេត្តកំពង់ចាម ខាងត្បូងនឹងខេត្តព្រៃវែង។ បច្ចុប្បន្នខេត្តត្បូងឃ្មុំ មាន ០១ក្រុង ០៦ស្រុក ០២សង្កាត់ និង ៦២ឃុំ ស្មើនឹង ៨៧២ភូមិ ។

ខេត្តត្បូងឃ្មុំមានផ្ទៃដីសរុបចំនួន ៥,២៥០.៥១គីឡូម៉ែត្រការេ មានអំណោយផលធម្មជាតិយ៉ាងល្អប្រសើរដល់ដំណាំកសិកម្ម ដំណាំស្បៀង និងកសិឧស្សាហកម្មផងដែរ។ ខេត្តត្បូងឃ្មុំមានទន្លេមេគង្គហូរកាត់ពីស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មារ ដែលនាំដីល្បាប់មានជីជាតិមកចាក់ចូលក្នុងតំបន់វាលទំនាបសម្រាប់កសិករធ្វើកសិកម្ម ខេត្តត្បូងឃ្មុំមានគ្រួសារសរុបចំនួន ១៩៣,៩៤០ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ៨៥៧,៩៨៤ នាក់ ចំនួនស្រ្តីសរុប ៤៣១,២៧៨ នាក់ ក្នុងនោះគ្រួសារក្រ១ និងក្រ២ មានចំនួន ២៩ ៧១២គ្រួសារ ស្មើនឹង ១៦,៥០% នៃគ្រួសារសរុប រីឯប្រាក់ចំណូលប្រចាំឆ្នាំក្នុងមនុស្សម្នាក់ស្មើនឹង ១,១៥០ ដុល្លារ។

## I- លទ្ធផលសម្រេចបាន ៖

### ១. ការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាព

**+ ការងាររដ្ឋបាល និងបុគ្គលិក**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំមានមន្ត្រីសរុបចំនួន ២២ រូប ស្រី ០៤ រូប ក្នុងនោះមាន៖

១- ប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០៣ រូប ( ស្រី ០០រូប)

២- មន្ត្រីបម្រើការងារនៅតាមការិយាល័យជំនាញទាំង ១០ ការិយាល័យចំណុះឱ្យមន្ទីរសរុបមានចំនួន ១៨រូប ស្រី ០៤រូប (ប្រធានការិយាល័យជំនាញ ១០នាក់ ស្រី ០២នាក់ អនុប្រធានការិយាល័យ ០៧នាក់ ស្រី ០២នាក់ និងមន្ត្រី ០១នាក់ ស្រី ០០នាក់) ដោយចែកចេញជា ១០ការិយាល័យ រួមមាន៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
- ការិយាល័យផ្លូវជនបទ
- ការិយាល័យផែនការ និងស្ថិតិ
- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ

- ការិយាល័យថែទាំសុខភាពជនបទ
- ការិយាល័យអភិវឌ្ឍន៍សហគមន៍
- ការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិច
- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

ក-ផ្នែកការងាររដ្ឋបាល

- ទទួលលិខិតចូលពីអង្គភាពនានាក្រោមន្ទីរ ចំនួន **២៦៦** លេខ
- ទទួលលិខិតចូលពីក្រសួងនិងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន **០៥២** លេខ
- ទទួលលិខិតចូលស្តីពី ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹង លិខិតអំពាវនាវ ចំនួន **០៤៨** លេខ

ខ-ចុះលេខលិខិតចេញ

- ចុះប្រភេទលិខិតចេញទៅបណ្តាអង្គភាពនានាក្រោមន្ទីរ ចំនួន ២២២លេខ
- ចុះប្រភេទលិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រី ចំនួន ៣៣១ លេខ
- ចុះប្រភេទលិខិតចេញទៅក្រសួង និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ០២៧លេខ
- ចុះប្រភេទលិខិតអញ្ជើញចេញទៅក្នុងអង្គភាពនានា សេចក្តីជូនដំណឹង សារលែកទុក្ខ លិខិតជូនពរ ចំនួន ០១៥ លេខ
- ចុះប្រភេទលិខិតចេញរបាយការណ៍ទៅក្រសួង អង្គភាពនានា ៖ចំនួន ០៤៩ លេខ

\+ ការងារបុគ្គលិក

- បានធ្វើសំណើសុំពិនិត្យលើប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេង ប្រចាំខែជូនមន្ត្រីរាជការ
- បានធ្វើរបាយការណ៍វឌ្ឍនភាពសម្រាប់បើកផ្តល់បៀវត្សជូនមន្ត្រីរាជការជូនក្រសួង
- បានធ្វើរបាយការណ៍វត្តមានប្រចាំខែជូននាយកដ្ឋាន
- បានធ្វើសេចក្តីសម្រេចស្តីពីរបៀបរបបការងារនិងការបែងចែកភារកិច្ចថ្នាក់ដឹកនាំអង្គភាពរចនាសម្ព័ន្ធគ្រប់គ្រងជូនក្រសួង
- បានធ្វើសំណើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ឆ្នាំ២០២៣ ទៅក្រសួង

**+ ការងារផែនការ**

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣ - ២០២៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។
- រៀបចំផែនការថវិកាកម្មវិធី ប្រចាំឆ្នាំ២០២៣ ។
- រៀបចំរបាយការណ៍ ៥ឆ្នាំ (ឆ្នាំ២០១៨- ២០២២) ជូនរដ្ឋបាលខេត្ត។
- រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឆ្នាំ២០២៣-២០២៥ ។
- ចូលរួមសិក្ខាសាលានានាតាមប្រពន្ធ័ Zoom បានចំនួន ០២ដង ។
- វគ្គបណ្តុះបណ្តាលនានា បានចំនួន ០១ដង ។
- ចូលរួមកម្មវិធីប្រជុំនានាតាមប្រព័ន្ធអនឡាញ Zoom បានចំនួន ៤ដង ។
- ចូលរួមកម្មវិធីប្រជុំនៅខេត្តត្បូងឃ្មុំ ចំនួ ១២ដង ។
- ចូលរួមកម្មវិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០២២ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តនៅទីលានបាល់ទាត់វិទ្យាល័យសម្តេចម៉ៃ ក្នុងឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

- ចូលរួមកិច្ចប្រជុំស្តីពី ការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ប្រចាំឆមាសទី១ ឆ្នាំ២០២២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។
- ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣ -២០២៥ និងថវិកា សមិទ្ធកម្មឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារឆ្នេរសុខា ខេត្តព្រះសីហនុ ។
- ចូលរួមកម្មវិធីចែកគ្រាប់ពូជស្រូវជូនដល់ប្រជាកសិករចំនួន ៦៧ គ្រួសារ នៅវត្តធុតង្គ ស្ថិតក្នុងភូមិត្បូង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ។
- ចូលរួមកម្មវិធីអបអរសាទរខេត្តព្រៃវែងទទួលបានជ័យលាភី ជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) នៅស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តព្រៃវែង។
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំ៩ខែ និងប្រចាំឆ្នាំ ជូនទៅក្រសួងអភិវឌ្ឍន៍ជន និងរដ្ឋបាលខេត្ត ។

**+ ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

ការអនុវត្តថវិកានៅក្នុងឆ្នាំ ២០២២មានៈ

- ជំពូក ៦០ ការទិញ ១៨៩ ២៦៧ ០០០ រៀល ស្មើនឹង ៩៨,០០%
- ជំពូក ៦១ សេវាកម្ម ៦៣៣ ៩៤០ ០០០ រៀល ស្មើនឹង ៩៦,២៩%
- ជំពូក ៦៣ ពន្ធ និងអាករ ៤០០ ០០០ រៀល ស្មើនឹង ២០,០០%
- ជំពូក ៦៤ បន្ទុកបុគ្គលិក ៣៩៩ ០០០ ០០០ រៀល ស្មើនឹង ៩៧,៦០%

**+ ការងារយេនឌ័រ**

- ចូលរួមសិក្ខាសាលាស្តីពី ការបញ្ជ្រាបយេនឌ័រ រយៈពេល ២ថ្ងៃ នៅសាលាខេត្តត្បូងឃ្មុំ។
- ចូលរួមកិច្ចប្រជុំរៀបចំសិក្ខាសាលាណែនាំគម្រោងនៅភូមិគោលដៅរបស់គម្រោង ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ( WEE) នៅមន្ទីរកិច្ចការនារី ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌យេនឌ័រ រដ្ឋបាលថ្នាក់ក្រោមជាតិ នៅសាលាខេត្តត្បូងឃ្មុំ។
- ចូលរួមកិច្ចប្រជុំបច្ចេកទេសសម្រាប់វគ្គបណ្តុះបណ្តាល ផែនការអាជីវកម្មខ្នាតតូច ការកត់ត្រាចំណូល-ចំណាយ របស់គម្រោងបង្កើនភាពអង់អាច ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី(WEE) ។
- វគ្គបណ្តុះបណ្តាលស្តីពី កាធ្វើអាជីវកម្មខ្នាតតូច ឬ គ្រួសារ និងការការកត់ត្រាចំណូល-ចំណាយរបស់គម្រោងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី( WEE)នៅភូមិអូរឡោក ឃុំចក ស្រុកអូររាំងឪ និងនៅវត្តសេដាសែនជ័យ ឃុំសេដា ស្រុកតុះបែរ ។

**២. ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

**+ ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ**

- សាងសង់ផ្លូវបេតុង ចំនួន ០៥ ខ្សែ ប្រវែងសរុប ៣៥ ៦០០ ម៉ែត្រ ក្នុងស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មារ។

- សាងសង់ផ្លូវកៅស៊ូចំនួន ១៣ ខ្សែ ប្រវែងសរុប ១៣៩ ២១០ ម៉ែត្រ ស្ថិតក្នុងស្រុកត្បូងឃ្មុំ អូររាំងឪ មេមត់ តំបែរ ក្រូចឆ្មារ និងពញាក្រែក។
- សាងសង់ផ្លូវកៅស៊ូ ចំនួន ០២ខ្សែ ប្រវែងសរុប ២១,៨០គីឡូម៉ែត្រ ក្នុងស្រុកក្រូចឆ្មារ និងស្រុកតំបែរ សម្រេចបាន៤០% (កំពុងអនុវត្ត) ។
- ជួសជុលខួបផ្លូវក្រួសក្រហម ចំនួន ០២ខ្សែ ប្រវែងសរុប ១៦ ២០០ ម៉ែត្រ ក្នុងស្រុកពញាក្រែក ស្រុកតំបែរ និងស្រុកត្បូងឃ្មុំ។
- ជួសជុលប្រចាំផ្លូវក្រួសក្រហម ចំនួន ១៥ខ្សែ ប្រវែងសរុប ១២២ ០០០ ម៉ែត្រ ក្នុងស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកមេមត់ ស្រុកតំបែរ ស្រុកក្រូចឆ្មារ ស្រុកអូររាំងឪ និងស្រុកពញាក្រែក ។
- សាងសង់ផ្លូវជើស ប្រវែងសរុប ១៧ ៨១០ ម៉ែត្រ ក្នុងស្រុកក្រូចឆ្មារ និងតំបែរ។
- សាងសង់ផ្លូវក្រួសក្រហម ប្រវែងសរុប ៩ ០៨០ ម៉ែត្រ ក្នុងស្រុកមេមត់ និងស្រុកក្រូចឆ្មារ ។
- ជួសជុលបន្ទាន់ផ្លូវក្រាលក្រួសក្រហម ចំនួន ០២ ខ្សែ ប្រវែង ៦ ០០០ ម៉ែត្រ ក្នុងស្រុកក្រូចឆ្មារ។

**៣. ការងារកែលម្អលក្ខខណ្ឌនៃការរស់របស់សហគមន៍ជនបទ**

**+ ការងារសាងសង់អណ្តូងទឹកជន់នឹងការប្រែប្រួលអាកាសធាតុ**

- ចូលរួមសិក្ខាសាលារៀនសូត្រតាមរយៈប្រព័ន្ធ Zoom ចំនួន ០១ ដង។
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយចំនួន ០១ ដង នៅខេត្តសៀមរាប ។
- ចូលរួមកិច្ចប្រជុំនានាតាមរយៈប្រព័ន្ធ Zoom ចំនួន ២ ដង ។
- បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន ០១ ដង ។
- ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត សុខភាព និងអនាម័យជនបទ ខេត្តត្បូងឃ្មុំ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ ចំនួន ០១ដង ។
- ចុះសិក្សាទីតាំងសម្រាប់សាងសង់ និងស្តារស្រះសហគមន៍ចំនួន ១២ កន្លែងនៅស្រុកក្រូចឆ្មារ ស្រុកមេមត់ ស្រុកតំបែរ ស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ និងស្រុកអូរាំងឪ។
- ចុះធ្វើការអង្កេតតាមគ្រួសារអំពីស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ និងផលប៉ះពាល់ដោយ សារជំងឺរាតត្បាតកូវីដ-19 នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទរបស់ធនាគារ AIIB ចំនួន១២ ភូមិ នៅស្រុកក្រូចឆ្មារ ស្រុកតំបែរ ស្រុកមេមត់ ស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ និងស្រុកអូរាំងឪ។
- ចុះផ្សព្វផ្សាយផលប៉ះពាល់បរិស្ថាន និងសង្គមក្នុងការសាងសង់និងស្តារស្រះសហគមន៍នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទរបស់ធនាគារ AIIB ចំនួន ១២ កន្លែងនៅស្រុកក្រូចឆ្មារ ស្រុកមេមត់ ស្រុកតំបែរ ស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ និងស្រុកអូរាំងឪ ។
- ចុះធ្វើលិខិតបញ្ជាក់ទីតាំងគ្រោងសាងសង់ និងស្តារឡើងវិញស្រះសហគមន៍ជូនដល់គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទចំនួន ១២កន្លែង នៅស្រុកក្រូចឆ្មារ ស្រុកមេមត់ ស្រុកតំបែរ ស្រុកពញាក្រែក និងស្រុកត្បូងឃ្មុំ។

- ចុះសិក្សានិង ត្រួតពិនិត្យទីតាំងសម្រាប់សាងសង់ និងស្តារឡើងវិញស្រះសហគមន៍ នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទដំហ៊ានទី២ ចំនួន ១៣កន្លែង នៅស្រុកក្រូចឆ្មារ ស្រុកតំបែរ និងស្រុកពញាក្រែក ។
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវរបស់គម្រោងឆ្នាំ២០២២ ចំនួន ១៣អណ្តូង នៅស្រុកត្បូងឃ្មុំ ស្រុកពញាក្រែក ស្រុកតំបែរ និងស្រុកមេមត់។
- ចុះសិក្សា ត្រួតពិនិត្យ និងកំណត់ទីតាំងសម្រាប់សាងសង់អណ្តូងស្នប់អាហ្វ្រីដេវថ្មី ចំនួន ១៤កន្លែង សម្រាប់ឆ្នាំ២០២៣។

**+ ការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ ឱ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទ**

- បានចូលរួមកិច្ចប្រជុំចំនួន ២ លើក តាមប្រព័ន្ធអនឡាញ Zoom Meeting ។
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ជនបទតាមរយៈប្រព័ន្ធបញ្ជូនសម្លេងនិងរូបភាព (Zoom Meeting)
- បានចូលរួមសិក្ខាសាលា ចំនួន ៣លើក (ខេត្តសៀមរាប២លើក និងខេត្តពោធិ៍សាត់១លើក)
- បានចុះទៅជួយបំផុសសកម្មភាពអនាម័យ Triggering នៅខេត្តក្រចេះ ដែលមានអ្នកចូលរួមចំនួន ៣៥ នាក់ ស្រី ១៧ នាក់ ។
- បានទៅចូលរួមពិធីប្រកាសទទួលស្គាល់ខេត្តព្រៃវែង ជាខេត្តដែលបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល នៅសាលប្រជុំគណៈកម្មាធិការគណៈបក្សប្រជាជនខេត្តព្រៃវែង។
- បានរៀបចំកិច្ចប្រជុំគណៈកម្មការទឹកស្អាត និងអនាម័យខេត្តប្រចាំត្រីមាសទី៣ ឆ្នាំ ២០២២ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទ ដែលមានអ្នកចូលរួម ចំនួន៤៧ នាក់ ស្រីចំនួន ០៩នាក់។
- បានចូលរួមកិច្ចប្រជុំក្រុមការងារពិសេសលុបបំបាត់ជំងឺគ្រុនចាញ់ ថ្នាក់ខេត្ត នៅមន្ទីរសុខាភិបាល ខេត្តត្បូងឃ្មុំ ចំនួន ៣លើក ។
- បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន ២លើក នៅសាលាខេត្តត្បូងឃ្មុំ។
- បានទៅចូលរួមវគ្គបណ្តុះបណ្តាលចំនួន ២លើក នៅស្រុកអូររាំងឪ។
- បានចុះទៅអប់រំផ្សព្វផ្សាយ និងជម្រុញដល់សហគមន៍អោយផ្លាស់ប្តូរទម្លាប់ ពីការបត់ជើងពាសវាលពាសកាលអោយមានបង្គន់អនាម័យប្រើប្រាស់ ចំនួន៧ លើកបានចំនួន ៨១ភូមិ ១៧ឃុំ ៣ស្រុក នៅក្នុងខេត្តត្បូងឃ្មុំ និងបានសាងសង់បង្គន់ចំនួន ១៨៤ បង្គន់ (ពញាក្រែក ៤លើក, អូររាំងឪ ២លើក និងត្បូងឃ្មុំ ១លើក) ។
- បានចូលរួមកម្មវិធីផ្សព្វផ្សាយគោលការណែនាំថ្នាក់ជាតិ ស្តីពីអនាម័យក្នុងបរិស្ថានប្រឈមសម្រាប់គ្រួសារជនបទ នៅឃុំឈូក ស្រុកក្រូចឆ្មារ ដែលមានអ្នកចូលរួមចំនួន ២២នាក់ ស្រីចំនួន ០៦នាក់ ។

- បានផ្តល់សម្ភារបង្គន់អនាម័យចំនួន ៣លើក ដែលមាន ១៦០បង្គន់ ដល់ភូមិបារាយណ៍ ៦០ភូមិ, ភូមិផ្កាដូង ៥០ភូមិ និងភូមិក្រឹបកៀក ៥០ភូមិ ក្នុងឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

**+ ការងារអភិវឌ្ឍន៍សហគមន៍**

- បានសម្របសម្រួលជាមួយលោកប្រធានក្រុមប្រឹក្សាឃុំសេដាសែនជ័យ ស្រុកតំបែរ ខេត្តត្បូងឃ្មុំដើម្បីផ្ទៀងផ្ទាត់ធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិសរុបចំនួន ២០ ភូមិ សរុបសមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិចំនួន ២៦នាក់ ក្នុងនោះ ស្រី៩ នាក់។
- ចូលរួមសិក្ខាសាលានានាតាមប្រពន្ធ័ Zoom បានចំនួន ០៦ដង។
- វគ្គបណ្តុះបណ្តាលនានា បានចំនួន ០៣ ដង ។
- ចូលរួមកម្មវិធីប្រជុំនានាតាមប្រពន្ធ័ Zoom online បានចំនួន ៨ ដង ។
- ចូលរួមកិច្ចសហការណ៍ជាមួយការិជំនាញ នានា បាន ០៦ ដង ។
- ចុះសម្របសម្រួលជាមួយគណៈកម្មការគម្រោងចលនាភូមិថ្មីទាំង១០ ភូមិ នៅស្រុកត្បូងឃ្មុំ ដែលមានលទ្ធផលដូចខាងក្រោម៖
    - ចូលរួមជួយសម្របសម្រួល បិទវគ្គក្រុមសន្សំប្រាក់ ប្រចាំឆ្នាំចំនួន ០២ ភូមិ ។
    - ចូលរួមត្រួតពិនិត្យបិទបញ្ជី ធនាគារជី និងថ្នាំបាញ់ស្មៅ ចំនួន ០៣ ភូមិ ។
    - ចូលរួមត្រួតពិនិត្យបញ្ជីគ្រប់គ្រងធនគារ គោ និងការផ្ទេរគោទៅសមាជិកថ្មីបន្តប្រចាំឆ្នាំ ចំនួន ០៥ ភូមិ ។
    - បន្តជួយជំរុញដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ត្រៀមរៀបចំរបាយការណ៍រីកចំរើនស្តីពី វឌ្ឍនភាពគម្រោងប្រចាំឆ្នាំ២០២១ ផ្ញើជូនមន្ទីរ និងក្រសួង ។

**៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

**+ ការងារលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឥណទានប្រចាំឆមាសទី១ និងទិសដៅបន្តឆ្នាំ២០២២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រង់ឥណទានជនបទនៅខេត្តសៀមរាប ។

**+ ការងារឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ៖**

- **ស្ថានភាពឥណទាន ៖**

- ការងារឥណទានជនបទត្រូវបានបង្កើតឡើងក្នុងគោលបំណងរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការ ផ្តល់សេវាឥណទានខ្នាតតូច សម្រាប់បង្កើត ពង្រីកមុខរបរ និង បង្កើនប្រាក់ចំណូលគ្រួសារក្នុងតំបន់ជនបទដោយបានទទួលមូលនិធិពីអង្គភាពអនុវត្តន៍គម្រោង ឥណទានខេត្តកំពង់ចាម ស្មើទឹកប្រាក់សរុបចំនួន **៨៩០ ០០០ ០០០ រៀល** (ប្រាំបីរយកៅសិបលានរៀលគត់) ស្មើ **២២២ ៥០០ ដុល្លា** (ពីររយម្ភៃពីរពាន់ប្រាំរយដុល្លា)។
- បច្ចុប្បន្នគម្រោងកំពុងប្រត្តិបត្តិការ ការងាររបស់ខ្លួន ជាពីរផ្នែកគឺ ៖

- **១- ឥណទានប្រជាពលរដ្ឋ** បានអនុវត្តន៍ក្នុងស្រុកគោលដៅចំនួនៈ ៤ គឺ ស្រុក ក្រូចឆ្មារ អូរាំងឪ ត្បូងឃ្មុំ និង ស្រុក ពញាក្រែក មាន១០ ឃុំ គឺឃុំកោខ្នុរ ស្រឡប់ ជីរោទិ៍ទី២ លៀង រការពប្រាំ ថ្មពេជ្រ ព្រះធាតុ គងជ័យ កណ្តោលជ្រុំ និងឃុំក្រែក និងភូមិចំនួន ២០ភូមិ ដែលកំពុងទទួលសេវាឥណទាន ពីអង្គភាពអនុវត្តន៍គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជន ។
- **២- ឥណទានមន្ត្រីរាជាមន្ត្រី** មាន ១៤ខេត្ត គឺ ខេត្តត្បូងឃ្មុំ(ក្រុងសួង) ខេត្តតាកែវ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ឆ្នាំង ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តមណ្ឌលគីរី ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ។

**+ ការងារអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច**

ចុះធ្វើបច្ចុប្បន្នភាពជនជាតិដើមភាគតិចនៅក្នុងស្រុកមេមត់ មាន ៖

- ភូមិទួលគ្រួស ឃុំជាំតាម៉ៅ ៖ ១៨១ គ្រួសារ ៦៦១ នាក់ ស្រី ២២៥ នាក់
- ភូមិបេងកោង ឃុំទន្លូង ៖ ៣១ គ្រួសារ ៣៣៥ នាក់ ស្រី ១១៥ នាក់
- ភូមិល្វាលើ ឃុំទន្លូង ៖ ២៨ គ្រួសារ ២៨៥ នាក់ ស្រី ១០០ នាក់

**សរុប ចំនួន ២ ឃុំ ៣ ភូមិ ២៤០ គ្រួសារ ១.២៨១ នាក់ ស្រី ៤ ៤០០ នាក់**

## II- បញ្ហាប្រឈម និងសំណូមពរ

- ខ្សែផ្លូវមួយចំនួនរងការខូចខាតដោយសារកត្តាទឹកជំនន់ទឹកភ្លៀង ទឹកជំនន់ទន្លេមេគង្គ
- ការដឹកលើសទម្ងន់ នៃយានយន្តដឹកទំនិញធំៗ និងកត្តាមិនចូលរួមថែរក្សារបស់ប្រជាជនមូលដ្ឋាន
- អណ្តូងស្នប់អាហ្វ្រីដេវ ខូចច្រើន
- ប្រជាពលរដ្ឋខ្វះថវិកាសាសង់បង្គន់
- ថវិកាគាំទ្រសម្រាប់បើកវគ្គបណ្តុះបណ្តាលមានកំណត់គឺ១ឆ្នាំទទួលបានតែ៥ វគ្គទៅ៦ វគ្គ (ថវិការបស់នាយកដ្ឋាន)
- ប្រជាពលរដ្ឋខ្ចីប្រាក់មួយចំនួនចំណាកស្រុកទៅឆ្ងាយ
- អតិថិជនមានបញ្ហាមុខរបររបស់គាត់បរាជ័យ និងផលិតផលចុះថោក
- ស្ថាប័ន អង្គការផ្សេងៗធ្វើប្រតិបត្តិការឥណទាន មានច្រើនក្នុងភូមិគោលដៅ
- ប្រជាពលរដ្ឋមួយចំនួនខ្ចីប្រាក់គ្រួតច្រើនស្ថាប័ន

## III- ទិសដៅការងារឆ្នាំ ២០២៣

- សាងសង់ផ្លូវក្រាលកៅស៊ូ២ ជាន់ មានចំនួន ៣២ ខ្សែ ប្រវែងសរុប ១៨២,៨៦០ ម៉ែត្រ ។
- បន្តចុះអនុវត្តន៍ការជួសជុល និងសាងសង់ផ្លូវឆ្នាំ២០២៣ និងការងារគម្រោងផ្សេងៗ បន្តទៀត។
- បន្តការចុះពិនិត្យតាមដានអណ្តូង ស្រះនិងប្រឡាយដែលបានសាងសង់រួច ។
- សហការណ៍ជាមួយថ្នាក់ស្រុកដើម្បីប្រមូលទិន្នន័យគ្រួសារក្រីក្រមានទឹកប្រើប្រាស់កម្រិតមូលដ្ឋាន

- បន្តការចុះពិនិត្យតាមដានអណ្តូង ស្រះសហគមន៍ និងប្រឡាយដែលបានសាងសង់រួច។
- បន្តសាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ។
- បណ្តុះបណ្តាល CLTS ( សហគមន៍ដឹកនាំអនុវត្តអនាម័យ ) ។
- ឧបត្ថម្ភសម្ភារបង្គន់អនាម័យដល់ឃុំទួលស្នួល និងឃុំឈូក ស្រុកក្រូចឆ្មារ ។
- ចុះជំរុញការសាសង់បង្គន់អនាម័យ ។
- បន្តជំរុញធ្វើបច្ចុប្បន្នភាព (គ.អ.ភ) ។
- បន្តសហការជាមួយអង្គការដៃគូក្នុងការជំរុញសហគមន៍ដឹកនាំអនុវត្តន៍អនាម័យ ។
- បើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពដល់សមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។
- បន្តផ្សព្វផ្សាយគម្រោងអភិវឌ្ឍន៍កសិកម្មចម្រុះ ដល់ភូមិគោលដៅ ។
- ចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច ស្ថិតក្នុងឃុំ ទន្លូង ស្រុកមេមត់។
- ខិតខំប្រឹងប្រែងអនុវត្តន៍ការងារដែលក្រសួង មន្ទីរ និងគណៈកម្មការគ្រប់គ្រងគម្រោងប្រគល់អោយសម្រេចបានកំរិតខ្ពស់ ។
- ខិតខំប្រឹងប្រែងបញ្ចេញឥណទានប្រកបដោយគុណភាព និងប្រមូលត្រឡប់មកវិញទទួល
- នូវអត្រាសងត្រឡប់ធំជាង ៩៨ % និងអត្រាហានិភ័យទាបជាង ២% ។
- បន្តបង្កើនការចុះដោះស្រាយបំណុលសងយឺតយ៉ាវមិនតាមការកំណត់អោយទទួលបានកម្រិតខ្ពស់ ។
- ពង្រឹងសមត្ថភាពបន្ថែមដល់មន្ត្រីភ្នាក់ងារពីការវាយតម្លៃអតិថិជនដើម្បីរួមចំណែកកាត់បន្ថយហានិភ័យឥណទាន។
- ផ្សព្វផ្សាយពីនិតិវិធី និងគោលការណ៍ឥណទាន ដល់មេឃុំ មេភូមិ គណៈកម្មការឥណទាន ភូមិក្នុងតំបន់គោលដៅរបស់គម្រោង ដើម្បីរួមចំណែកកាត់បន្ថយការខ្ចីប្រាក់ត្រួតស៊ីគ្នាច្រើនស្ថាប័ន។
- ផ្សព្វផ្សាយដល់សហគមន៍ពីការចងក្រងបង្កើតក្រុមសន្សំប្រាក់ជួយខ្លួនឯង ។

## សេចក្តីសន្និដ្ឋាន

លទ្ធផលដែលសម្រេចបានក្នុងរយៈពេល ១ ឆ្នាំកន្លងមកនេះ គឺពិតជាមកពីការខិតខំយកចិត្ត ទុកដាក់ក្នុងការបំពេញភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ របស់មន្ត្រីរាជការ បុគ្គលិកនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ពិសេសការដឹកនាំ ណែនាំដោយផ្ទាល់ប្រកបដោយភាពម៉ឺងម៉ាត់ឆ្លាតវៀងវៃមានតម្លាភាព និងមានប្រសិទ្ធិភាពរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាប្រមុខដឹកនាំរបស់ក្រសួង ក៏ដូចជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់ក្រសួង និងនាយកដ្ឋានជំនាញនានារបស់ក្រសួង ដែលបានជួយបង្កគ្រប់លក្ខណៈសម្បត្តិ ងាយស្រួលទាំងស្មារតីសម្ភារៈ និងថវិកា ដែលជាប្រភពទុនដ៏សំខាន់អាចឲ្យមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំធ្វើការងារអភិវឌ្ឍន៍នៅមូលដ្ឋានទទួលបានលទ្ធផលល្អ និងមានការរីកចម្រើនជារៀងរាល់ឆ្នាំ។

ដោយអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជនបទរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ គឺទទួលបានការអភិវឌ្ឍន៍មានដូចជា ស្ពាន និងផ្លូវលំជនបទ ខ្វាត់ខ្វែងសម្រាប់ប្រជាពលរដ្ឋធ្វើចរាចរណ៍ ក្នុងការដឹកនាំកសិផលដែលជាកត្តាធ្វើអោយប្រជាពលរដ្ឋទៅកាន់តែជិតរវាងជនបទ និងទីក្រុង ធ្វើឱ្យប្រជាជនមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ ជាពិសេសធ្វើអោយការយល់ដឹងពីសុខភាព និងអនាម័យតាម រយៈការ អប់រំ ផ្សព្វផ្សាយ និងប្រើប្រាស់បង្គន់អនាម័យ ។

លទ្ធផលទាំងអស់នេះពិតជាបានរួមចំណែក លើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យបានល្អប្រសើរជាងមុន និងបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមជនបទ ស្របតាមគោលដៅគោលនយោបាយជាយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ១០ ឆ្នាំ (២០២១-២០៣០) ធ្វើឲ្យប្រជាពលរដ្ឋនៅជនបទមានភាពស៊ីវិល័យ ។

**ប្រធានមន្ទីរ**

ចម្លងជូន
- គ្រប់នាយកដ្ឋាននៃក្រសួងអភិវឌ្ឍន៍ជនបទ
- គ្រប់ការិយាល័យជំនាញ របស់មន្ទីរ

  ៉ដើម្បីជូនជ្រាប៉

- ឯកសារ-កាលប្បវត្តិ